ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២០ លេខ ១ ខែមីនា ២០១៦ តម្លៃ ១.៥០០៛

# ការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅជនបទកម្ពុជា៖ ផលប៉ះពាល់លើទិន្នផលស្រូវ និងចំណូលពីផលដំណាំ

## សេចក្ដីផ្ដើម

តាំងពីដើមរៀងមក កសិកម្មជាវិស័យសំខាន់ជាងគេនៅក្នុងសេដ្ឋកិច្ចកម្ពុជា ដោយសារប្រជាជនភាគច្រើនលើសលុប រស់នៅតាមតំបន់ជនបទ។ ដីធ្លីនៅតែជាកត្តាស្នូលសម្រាប់ជីវភាពប្រជាជននៅជនបទ ព្រោះវាមិនត្រឹមតែជាប្រភពនៃសេដ្ឋកិច្ចចិញ្ចឹមពោះ និងសុវត្ថិភាពទ្រព្យធនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាមធ្យោបាយដ៏សំខាន់មួយនៃការបង្កើនធនធានទៀតផង (Deininger and Binswanger 1999)។



សុវត្ថិភាពការកាន់កាប់ដីធ្លី សម្រួលដល់ការដាក់បញ្ចាំកម្ចី របររកស៊ី ធ្វើផ្ទះសម្បែង ទិន្នផលស្រូវ និងចំណូលពីផលដំណាំ ខេត្តកណ្ដាល ខែឧសភា ឆ្នាំ២០១៥

មកទល់ឆ្នាំ២០០១ ក្នុងចំណោមដីធ្លីនៅប្រទេសកម្ពុជាទាំងមូល មានត្រឹម ១០% ប៉ុណ្ណោះដែលមានប័ណ្ណកម្មសិទ្ធិ។ ហេតុនេះ នៅឆ្នាំ២០០២ រដ្ឋាភិបាលកម្ពុជា បានចាប់ផ្ដើមកម្មវិធីចុះបញ្ជីដីធ្លីជាប្រព័ន្ធថ្មីមួយ ដោយមានជំនួយទ្រទ្រង់ពីដៃគូអភិវឌ្ឍន៍ ដូចជា ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងប្រទេសផ្សេងៗ មានជាអាទិ៍ អាល្លឺម៉ង់ ស៊ុយអែត ដាណឺម៉ាក ជប៉ុន និង កូរ៉េខាងត្បូង (Thomson 2010)។ កិច្ចប្រឹងប្រែងចុះបញ្ជីដីធ្លី កំពុងដំណើរការទៅមុខនេះ សំដៅផ្ដល់នូវសន្តិសុខដីធ្លីឲ្យបានកាន់តែប្រសើរក្នុងទូទាំងប្រទេស និងជំរុញទីផ្សារដីធ្លីនៅជនបទ (Sar 2010)។ កម្មវិធីចុះបញ្ជីដីធ្លីថ្មីនេះ ក៏ជួយធ្វើឲ្យសាមញ្ញផងដែរនូវ នីតិវិធីចុះបញ្ជីដីធ្លីសម្រាប់ម្ចាស់ដីនានា។

ចំណុចសំខាន់មួយគួរស្វែងយល់ គឺការអនុវត្តការចុះបញ្ជីដីធ្លីជាផ្លូវការទ្រង់ទ្រាយធំ វាមានប៉ះពាល់បែបណាទៅលើផលិតភាពកសិកម្មនៅតំបន់ជនបទ។ ទោះបីពេលវេលាបានកន្លងទៅជិត ១៥ឆ្នាំហើយក្ដី ក៏ប្រធានបទនេះនៅតែមិនទាន់មានការសិក្សាស្រាវជ្រាវឲ្យបានគ្រប់គ្រាន់។ ការសិក្សានេះសំដៅពិនិត្យពីផលប៉ះពាល់នៃកម្មវិធីចុះបញ្ជីដីធ្លីនៅជនបទកម្ពុជា។ ការពិនិត្យជារួមពីលំនាំតាំងពីដើមរៀងមកនៃការកាន់កាប់ដីធ្លីនៅកម្ពុជា និងការសិក្សាដោយសង្ខេប លើឯកសារពាក់ព័ន្ធនឹងការកាន់កាប់ដី និងកម្មសិទ្ធិដី ជួយបង្ហាញពីសាវតាខ្លះៗ និងកត្តាជំរុញដល់ការសិក្សានេះ។ បន្ទាប់មកទៀត មានការបង្ហាញពីលទ្ធផលរកឃើញសំខាន់ៗ និងការពិភាក្សាពីឥទ្ធិពលនៃកម្មវិធីចុះបញ្ជីដីធ្លីទៅលើផលកសិកម្ម ហើយនៅផ្នែកចុងក្រោយ មានផ្ដល់នូវសេចក្ដីសន្និដ្ឋាន។

## សាវតានៃសិទ្ធិកាន់កាប់ដីធ្លី

មុនពេលស្ថិតក្រោមរបបអាណានិគមបារាំង ប្រជាជនទូទៅអាចកាន់កាប់ បន្តមរតក លក់ និងដាំដុះលើដីដោយជាក់ស្តែង

អត្ថបទនេះ ចងក្រងឡើងដោយ ស្រ៊ី បុប្ផារ័ត្ន អ្នកស្រាវជ្រាវផ្នែកសេដ្ឋកិច្ច នៃ CDRI ដោយប្រើប្រាស់ព័ត៌មានបានពីការសិក្សារបស់ Sry (2013)។ សូមយោងឯកសារនេះថា៖ Sry Bopharath. 2016. "On Systematic Land Titling in Rural Cambodia: Its Impact on Rice Yield and Crop Revenue." *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* 20(1): 1-5. ភ្នំពេញ វិទ្យាស្ថាន CDRI។

## មាតិកា

ការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅជនបទកម្ពុជា៖ ផលប៉ះពាល់លើទិន្នផលស្រូវ និងចំណូលពីផលដំណាំ ........ ១
ការវិភាគផ្អែកតាមបទពិសោធន៍ជាក់ស្ដែងលើ កត្តាកំណត់ការជ្រើសយកប្រភេទផ្សេងៗនៃសកម្មភាពរកប្រាក់ចំណូលក្រៅពីមុខរបរស្រែចំការ នៅតំបន់ជនបទក្នុងប្រទេសកម្ពុជា ........ ៦
ឧបសគ្គរារាំងការលើកកម្ពស់រូបិយវត្ថុក្នុងស្រុក៖ ការសិក្សាប្រៀបធៀបនឹងប្រទេសបូលីវី អេក្វាទ័រ និងប៉េរូ ........ ១៣
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស ........ ១៩
– ស្ថានភាពក្នុងប្រទេស ........ ២១
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........ ២៨

បាន ប៉ុន្តែដីទាំងអស់ជាកម្មសិទ្ធិរបស់ព្រះមហាក្សត្រ ហើយមិនមានការចុះបញ្ជីជាផ្លូវការនូវសិទ្ធិកាន់កាប់ដីឯកជនឡើយ។ នៅជិតចុងសតវត្សរ៍ទី១៩ បារាំងបានចាប់ផ្តើមរៀបចំឲ្យមានច្បាប់គ្រប់គ្រងសិទ្ធិកាន់កាប់ដីធ្លី ដើម្បីកាត់បន្ថយអំណាចព្រះមហាក្សត្រ និងបង្កើតចំណូលពន្ធ (Chandler 2008, 174)។ ច្បាប់ភូមិបាលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៨៨៤ ប៉ុន្តែ រហូតដល់ទសវត្សរ៍១៩៣០ ទើបមានការដាក់អនុវត្តជាក់ស្តែង ដោយនៅពេលនោះ ដីស្រែភាគច្រើន ត្រូវបានចុះបញ្ជីជាទ្រព្យឯកជន ហើយម្ចាស់ដីអាចលក់ដីរបស់ខ្លួនដោយពេញសិទ្ធិបាន។

ក្រោយកម្ពុជាទទួលបានឯករាជ្យ ប្រព័ន្ធចុះបញ្ជីដីធ្លីខាងលើនេះបានបន្តអនុវត្តរហូតដល់ឆ្នាំ១៩៧៥។ ជំរឿនថ្នាក់ជាតិ ឆ្នាំ១៩៦២ មានកត់ត្រានូវ ក្បាលដីកសិកម្ម ៨០០.០០០ឡូត៍ ដែលក្នុងនោះ ៨៤% ជាកម្មសិទ្ធិឯកជន (Sar 2010)។ នៅក្រោមរបបសម្ព័ហភាពជ្រុលនិយម តម្រូវឡើងដោយខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ (Frings 1994) កម្មសិទ្ធិដីឯកជនត្រូវបានលុបចោល ហើយឯកសារដីធ្លីភាគច្រើនត្រូវបំផ្លាញអស់ (Hap 2010)។ ទោះយ៉ាងណាក្តី ការជំនួសកម្មសិទ្ធិឯកជនដោយកម្មសិទ្ធិសមូហភាពនេះ មានអាយុកាលខ្លីណាស់។ តម្រូវការសេរីភាវូបនីយកម្មសេដ្ឋកិច្ចកាន់តែលេចច្បាស់ឡើង នាំឲ្យមានការបង្កើតច្បាប់អនុញ្ញាតកម្មសិទ្ធិឯកជនលើអចលនទ្រព្យវិញ នៅឆ្នាំ១៩៨៩ (Gottesman 2004)។ នៅឆ្នាំ១៩៩២ មានការធ្វើកំណែទម្រង់ច្បាប់ភូមិបាលឆ្នាំ១៨៨៤ ប៉ុន្តែក្នុងនោះ មិនមានសេចក្តីថែងពីប្រព័ន្ធគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព ឬក៏ព័ត៌មានសព្វគ្រប់ស្តីពីកម្មសិទ្ធិឯកជននោះទេ។ ទោះបីមានការបង្កើតរបបប្រជាធិបតេយ្យថ្មីនៅឆ្នាំ១៩៩៣ ក្តី ក៏មិនមានកំណែទម្រង់ដីធ្លីតាមផ្លូវច្បាប់ជាដុំកំភួនបន្ថែមអ្វីទៀតទេ គឺរហូតដល់ឆ្នាំ២០០១ ទើបមានការអនុម័តវិសោធនកម្មលើច្បាប់ភូមិបាល។

វិសោធនកម្មច្បាប់ភូមិបាលឆ្នាំ២០០១ បានបែងចែកកម្មសិទ្ធិដីធ្លីជាបីប្រភេទ៖ កម្មសិទ្ធិរដ្ឋ កម្មសិទ្ធិឯកជន និងកម្មសិទ្ធិសមូហភាព។ ដីរដ្ឋ រួមមាន ដីទាំងអស់ដែលមិនត្រូវបានបែងចែកទៅឲ្យឯកជន។ ដីរដ្ឋមានពីរប្រភេទ៖ ដីសាធារណៈរបស់រដ្ឋ (សម្រាប់ផលប្រយោជន៍សាធារណៈ) និងទ្រព្យឯកជនរបស់រដ្ឋ (កាន់កាប់ដោយរដ្ឋ)។ ដីសាធារណៈរបស់រដ្ឋ សម្រាប់ប្រើជាផលប្រយោជន៍សាធារណៈ និងរួមមាន បឹង ទន្លេ ស្ទឹង ដីព្រៃ តំបន់អភិរក្សធម្មជាតិ តំបន់បុរាណវិទ្យា តំបន់វប្បធម៌និងបេតិកភ័ណ្ឌ និងអគារសាធារណៈ ដូចជា មន្ទីរពេទ្យ សាលារៀន និងអគាររដ្ឋបាល ជាដើម។ ទ្រព្យឯកជនរបស់រដ្ឋ អាចលក់ដោះដូរ ឬជួលបាន ហើយអាចប្រើប្រាស់សម្រាប់ជាកម្មវត្ថុនៃកិច្ចសន្យាស្របច្បាប់ទាំងឡាយ ដូចជា សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គម រហូតដល់ ៩៩ឆ្នាំ (Cambodian Center for Human Rights 2013)។ ទ្រព្យឯកជន អាចប្រើសម្រាប់ផលិតកម្មដំណាំ ឬការស្នាក់នៅជាលក្ខណៈបុគ្គល ហើយអាចជាកម្មសិទ្ធិបុគ្គល ឬកម្មសិទ្ធិរួមគ្នា។ ផ្អែកតាមច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា ២៣ ដីទ្រព្យសមូហភាព រួមមាន ដីវត្តអារាម និងដីរបស់សហគមន៍ប្រជាជនដើមដែល "រស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព" (CDC, CIB and CSEZB 2016)។

ការចុះបញ្ជីដីធ្លីនៅកម្ពុជា ចែកចេញជាពីរប្រភេទ៖ លក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំ។ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធអនុវត្តឡើងមួយភូមិម្តងៗ តាមក្របខ័ណ្ឌពេលវេលាជាក់លាក់មួយ ចំណែកឯការចុះបញ្ជីដាច់ដោយដុំ អាចឲ្យបុគ្គលដាក់ពាក្យស្នើសុំចុះបញ្ជីដីនៅពេលណាក៏បាន។ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺផ្តួចផ្តើមឡើងដោយរដ្ឋាភិបាល ហើយការចុះបញ្ជីដីធ្លីដាច់ដោយដុំ ធ្វើឡើងតាមសំណើរបស់ម្ចាស់ដីនីមួយៗ។

រូបភាព១៖ នីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ




ប្រភព៖ MLMUPC 2013

## ការសិក្សាលើឯកសារពាក់ព័ន្ធ

ទ្រឹស្តីសេដ្ឋកិច្ច Neoclassical economic theory បានកំណត់ថា ចំណែកដីដែលគ្មានការទទួលស្គាល់តាមផ្លូវច្បាប់ជាផ្លូវការ គឺដូចជា "មូលធនងាប់" (Soto 2000)។ ដីកម្មសិទ្ធិឯកជន គួរតែធ្វើការចុះបញ្ជី ដើម្បីផ្លាស់ប្តូរមូលធនងាប់នេះ ឲ្យទៅជាមូលធនរស់វិញ។ Soto (2000) បានលើកនូវហេតុផលបីសម្រាប់ការចេញប័ណ្ណដីធ្លីស្របច្បាប់ឲ្យទៅប្រជាជនក្រីក្រ។ ទី១ ប្រជាជនត្រូវការនូវអារម្មណ៍មានសុវត្ថិភាពក្នុងការកាន់កាប់ដីរបស់ខ្លួន ទើបអាច

រូបភាព២៖ នីតិវិធីចុះបញ្ជីដីធ្លីដាច់ដោយដុំ




ប្រភព៖ Torhonen 2001

ធ្វើវិនិយោគទៅលើអាជីវកម្ម និងផ្ទះសម្បែងរបស់ខ្លួន។ ទី២ ការកាន់កាប់ដីស្របច្បាប់ វាកែប្រែដីឲ្យទៅជាទ្រព្យអាចដោះដូរបាន ដែលអាចប្រើប្រាស់ជាវត្ថុដាក់ធានា ដើម្បីយកប្រាក់កម្ចី។ ទី៣ តាមរយៈការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ការផ្តល់ប័ណ្ណកម្មសិទ្ធិគ្មានកាលកំណត់ ជួយឲ្យប្រទេសកំពុងអភិវឌ្ឍន៍អាចចេញផុតពីភាពក្រីក្រ។ ជាលទ្ធផល ប្រទេសជាច្រើន បានអនុវត្តកម្មវិធីចុះបញ្ជីដីធ្លី។ ការសិក្សាស្រាវជ្រាវជាក់ស្តែងមួយចំនួន រកឃើញថា ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ជួយបង្កើនផលកសិកម្ម វិនិយោគ និងការប្រើឥណទាន ប៉ុន្តែការសិក្សាខ្លះទៀតរកឃើញថា វាគ្មានឥទ្ធិពលសោះ ឬផ្តល់នូវលទ្ធផលចម្រុះ។

ឧទាហរណ៍ ដោយប្រើវិធីសាស្ត្រ difference-in-differences ដើម្បីវាយតម្លៃលើ កម្មវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅប្រទេសប៉េរូ ពីឆ្នាំ១៩៩៤ ដល់ ២០០០ នោះ Fort (2007) បានរកឃើញឥទ្ធិពលវិជ្ជមាននៃកម្មវិធីនេះ ទៅលើការធ្វើវិនិយោគជាលក្ខណៈបុគ្គល។ ស្រដៀងគ្នាដែរ Deininger and Jin (2006) បានបង្ហាញពី ឥទ្ធិពលវិជ្ជមាននៃកម្មសិទ្ធិដីធ្លី ទៅលើការធ្វើវិនិយោគនៅប្រទេសអេត្យូពី។ នៅវៀតណាម Do និង Iyer (2008) រកឃើញថា កំណែទម្រង់ដីធ្លីតាមរយៈការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ វាជះឥទ្ធិពលទៅលើ ការសម្រេចចិត្តធ្វើវិនិយោគរយៈពេលវែងរបស់គ្រួសារ ទៅក្នុងវិស័យកសិកម្ម។

ផ្ទុយមកវិញ Borrows and Roth (1990) រកឃើញថា មិនមានភាពខុសគ្នាអ្វីគួរឲ្យកត់សំគាល់នៅក្នុងវិនិយោគ និងផលិតភាពរវាងដីមានប័ណ្ណ នឹងដីមិនមានប័ណ្ណកម្មសិទ្ធិ នៅប្រទេសកេនយ៉ា អ៊ូហ្គង់ដា និងហ្ស៊ីមបាវ៉េ នោះទេ។ ពួកគេ លើកឡើងថា ការផ្គត់ផ្គង់ និងតម្រូវការវិនិយោគ មានកម្រិតទាប ដោយសារភាពមានខ្វះនៃទីផ្សារ និងបន្តទៀតថា វិនិយោគអាចត្រូវរាំងស្ទះ ដោយសារកង្វះវិធានច្បាប់សម្រាប់ការពារសិទ្ធិបុគ្គលក្នុងការទទួលបាន និងប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួន។

ឯកសារពាក់ព័ន្ធនានា ផ្តល់នូវភស្តុតាងខ្លះៗពី ផលប៉ះពាល់វិជ្ជមាននៃប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់ ទៅលើវិនិយោគ។ ការសិក្សាដោយ Markus and Udry (2008) នៅប្រទេសហ្គាណា រកឃើញថា ការកាន់កាប់ដីមានសុវត្ថិភាព វាជះឥទ្ធិពលទៅលើការធ្វើវិនិយោគលើដីធ្លី និងលើដីជាតិដី។ នៅប្រេស៊ីល ការមានប័ណ្ណកម្មសិទ្ធិដីផ្លូវការ មានទំនាក់ទំនងជាមួយកំណើនវិនិយោគលើដីធ្លី និងកំណើនថ្លៃដី (Alston, Libecap and Schneider 1996)។ Galiani and Schargrodsky (2010) បានបង្ហាញពី

បែបបទដែលប័ណ្ណកម្មសិទ្ធិដីនៅតំបន់ទីក្រុង ជំរុញឲ្យមានការធ្វើវិនិយោគទៅលើ ផ្ទះសម្បែង។ ការសិក្សាស្រាវជ្រាវរបស់ Markussen (2008) នៅកម្ពុជា បង្ហាញថា សិទ្ធិលើទ្រព្យសម្បត្តិមានឥទ្ធិពលវិជ្ជមាន និង មានទំនាក់ទំនងជាមួយផលិតភាពកសិកម្ម និងថ្លៃដី។

## វិធីសាស្ត្រសិក្សាស្រាវជ្រាវ

### *ទិន្នន័យ និងស្ថិតិបែបពណ៌នា*

ការសិក្សានេះ ប្រើទិន្នន័យបានពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៤ និង ២០០៨ និងព័ត៌មានបានពី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ទាក់ទងនឹងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅក្នុង ៣៣៨ភូមិ ពីឆ្នាំ២០០៤ ដល់ ២០០៨។

បណ្ដាក្រុមបានយកមកសិក្សា គឺមាន ភូមិដែលគេបានចេញប័ណ្ណកម្មសិទ្ធិដីឲ្យពីឆ្នាំ២០០៥ ដល់ ២០០៧ ហើយក្រុមទុកសម្រាប់ប្រៀបធៀប (control group) គឺភូមិទាំងឡាយដែលមិនស្ថិតក្នុងកម្មវិធីចុះបញ្ជីដីធ្លី។ បន្ទាប់ពីបានរៀបចំឲ្យមានតុល្យភាពគ្នាក្នុងលក្ខណៈសំគាល់សំខាន់ៗនៃក្រុមទាំងពីរមក ការសិក្សាបានសម្រេចជ្រើសយក ១៤ភូមិត្រូវសិក្សា (១២៩គ្រួសារ) និង ១៤៨ភូមិទុកសម្រាប់ប្រៀបធៀប (១៧៧៥គ្រួសារ)។ គ្រួសារប្រហែល ៨០% មានមេគ្រួសារជាបុរស ហើយអាយុមធ្យមនៃមេគ្រួសារគឺ ៤៦ឆ្នាំ។ អត្រាសមាជិកក្នុងបន្ទុកគឺ ៧៨% ដែលខ្ពស់ជាខ្លាំង។ គ្រួសារនីមួយៗមានដីកសិកម្មជាមធ្យម ០,៦ហិកតា ដែលភាគច្រើនជាដីសើម និងទទួលបានទិន្នផលស្រូវ ១,៦តោន/ហិកតា (តារាង១)។

### *ការធ្វើម៉ូដែលពីផលិតភាពកសិកម្ម និងផលប៉ះពាល់លើប្រាក់ចំណូល (សូមមើលឯកសារជាភាសាអង់គ្លេស)*

## លទ្ធផលរកឃើញជាក់ស្ដែង

ឥទ្ធិពលរំពឹងទុកដ៏សំខាន់មួយនៃ កម្មវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺកំណើនផលិតភាពកសិកម្ម។ លទ្ធផលរកឃើញជាក់ស្ដែង មិនមានផ្ដល់ភស្តុតាងអ្វីថា កម្មវិធីចុះបញ្ជីដីធ្លីមានជះឥទ្ធិពលវិជ្ជមានទៅលើទិន្នផលស្រូវ និងចំណូលពីផលដំណាំនោះទេ។

## សេចក្ដីសន្និដ្ឋាន

លទ្ធផលនៃការសិក្សានេះ មិនគាំទ្រដល់សម្មតិកម្មថា ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ វាមានផលប៉ះពាល់វិជ្ជមានទៅលើផលកសិកម្មនៃក្បាលដីនីមួយៗ ដូចមានលើកឡើងនៅក្នុងឯកសារពាក់ព័ន្ធជាច្រើនទៀតនោះទេ។ កម្មវិធីចុះបញ្ជីដីធ្លី ហាក់មិនមានរួមចំណែកអ្វីគួរឲ្យកត់សំគាល់ឡើយ នៅក្នុងកំណើនផលិតភាពកសិកម្មនៅកម្ពុជា។

បើគិតតាមលទ្ធផលអាចមើលឃើញ ការមិនសម្រេចបានតាមការរំពឹងទុក អាចគួរឲ្យខកចិត្តដែរ។ បទពិសោធន៍នៅកម្ពុជា មិនខុសគ្នាអ្វីច្រើនពីនៅ កេនយ៉ា អ៊ូហ្គង់ដា និង ហ្ស៊ីមបាវេ ទេ ព្រោះនៅប្រទេសទាំងនោះ កំណែទម្រង់ដីធ្លី ក៏មានផលប៉ះពាល់តិចតួចទៅលើផលិតកម្មកសិកម្មដែរ (Borrows and Roth 1990)។ ទោះបីជាកម្មវិធីនេះ បានអនុវត្តជាបន្តបន្ទាប់ តាំងពីឆ្នាំ២០០២មកក្ដី ក៏ការចេញប័ណ្ណកម្មសិទ្ធិដីជាផ្លូវការនៅជនបទកម្ពុជា នៅមានកម្រិតនៅឡើយ។ ដូច្នេះ គួរបង្កើនល្បឿនចុះបញ្ជីដីធ្លី ជាពិសេសសម្រាប់ម្ចាស់ដីតូចៗ ដើម្បីពង្រីកកម្មសិទ្ធិដីធ្លី និងពង្រឹងអត្ថប្រយោជន៍នៃការកាន់កាប់ដីមានសុវត្ថិភាព។

ទំនាក់ទំនងរវាងកម្មសិទ្ធិដីធ្លី នឹងកំណើនវិស័យកសិកម្ម ជាវិស័យថ្មីមួយសម្រាប់ការសិក្សាស្រាវជ្រាវនៅកម្ពុជា ហើយចំណេះដឹងដែលមានការសិក្សាស្រាវជ្រាវបញ្ជាក់គាំទ្រ គឺនៅមានកម្រិតនៅឡើយ។ កិច្ចប្រឹងប្រែងសិក្សាស្រាវជ្រាវទៅថ្ងៃអនាគតគួរមានការសិក្សាដោយប្រើទិន្នន័យបានពី អង្កេតនៅត្រង់ចំណុចមួយនៃពេលវេលា (cross sectional study) ក្នុងរយៈពេលមួយវែងគ្រប់គ្រាន់។

## ឯកសារយោង


Alston, L., D.G. Libecap and R. Schneider. 1996. “The Determinants and Impact of Property Rights: Land Titles on the Brazilian Frontier.” *The Journal of Law, Economics and Organization* 12(1): 25-61.

Angrist, D.J., and S.J. Pischke. 2009. *Mostly Harmless Economictrics: An Empiricist’s Companion.* New Jersey: Princeton University Press.

Borrows, R., and M. Roth. 1990. “Land Tenure and Investment in African Agriculture: Theory and Evidence.” *The Journal of Modern African Studies* 28(2): 265-297.

Cambodia Center for Human Rights. 2013. *Cambodia: Land in Conflict: An Overview of the Land Situaton.* Phnom Penh: Cambodia Center for Human Rights.

CDC, CIB and CSEZB. 2016. “Land Law.” Accessed 9 May 2016, www.cambodiainvestment .gov.kh/land-law_010430.html.

Chandler, D. 2008. *A History of Cambodia* (4th ed.). Boulder, CO: Westview.

Deininger, K., and H. Binswanger. 1999. “The Evolution of the World Bank’s Land Policy: Principles, Experience, and Future Challenges.” *The World Bank Research Observer* 14(2): 247-76.

Deininger, K., and S. Jin. 2006. Tenure Security and Land-Related Investment: Evidence from Ethiopia. *European Economic Review* 50:1245-1277.

Do, T.Q., and L. Iyer. 2008. Land Titling and Rural Transition in Vietnam. *Economic Development and Cultural Change* 56(3): 531-579.

Fort, R. 2007. *Property Rights after Market Liberalization Reforms: Land Titling and Investments in Rural Peru.* Wageningen: Wageningen Academic Publishers.

Frings, V. 1994. 1994. “Cambodia after Decollectivation (1989-1992). *Journal of Contemporary Asia* 24(1): 49-66.

Galiani, S., and E. Schargrodsky. 2010. “Property Rights for the Poor: Effects of Land Titling.” *Journal of Public Economics* 94(9-10): 700-729.

Gottesman, E. 2004. *Cambodia after the Khmer Rouge: Inside the Politics of Nation Building.* London: Yale University Press.

Hap, P. 2010.” Implementation of Cambodia’s Laws on Land Tenure.” Doctoral dissertation, Nagoya University.


តទៅទំព័រ ១០

## ឧបសម្ព័ន្ធ

តារាង A1៖ អថេរពណ៌នាសំខាន់ៗ ឆ្នាំ២០០៤ និង ២០០៨

| ក្រុមទុកសម្រាប់ប្រៀបធៀប | | | | | 2004 & 2008 |
|---|---|---|---|---|---|
| | មធ្យម (mean) | គម្លាតស្តង់ដា | អប្បបរមា | អតិបរមា | ចំនួន |
| ភេទមេគ្រួសារ (1=បុរស) | 0.81 | 0.40 | - | - | 2638 |
| អាយុមេគ្រួសារ (ឆ្នាំ) | 46.19 | 13.98 | 19 | 88 | 2638 |
| មេគ្រួសារចេះអាន និងសរសេរ (%) | 0.69 | 0.47 | - | - | 2638 |
| ទំហំគ្រួសារ (នាក់) | 4.95 | 1.96 | 1 | 14 | 2638 |
| អត្រាសមាជិកក្នុងបន្ទុក (%) | 0.78 | 0.69 | 0 | 5 | 2611 |
| កម្ចីផ្លូវការក្នុងមួយគ្រួសារ (ដុល្លារ) | 0.12 | 0.32 | - | - | 2638 |
| កម្ចីក្រៅផ្លូវការក្នុងមួយគ្រួសារ (ដុល្លារ) | 0.28 | 0.44 | - | - | 2638 |
| ទំហំក្បាលដី (ហិកតា) | 0.70 | 0.91 | 0.001 | 15 | 5221 |
| ផលិតកម្មស្រូវ (តោន/ហិកតា) | 1.74 | 1.08 | 0 | 5 | 3051 |
| ចំណូល (ដុល្លារ/ហិកតា) | 388.70 | 498.01 | 0 | 8981.35 | 5145 |
| ប្រភេទដី (ហិកតា) | | | | | |
| ដីសើម | 0.48 | 0.50 | - | - | 5221 |
| ដីស្ងួត | 0.15 | 0.35 | - | - | 5221 |
| ទាំងដីសើម និងស្ងួត | 0.04 | 0.19 | - | - | 5221 |
| **ចំការ** | 0.24 | 0.42 | - | - | 5221 |
| សួនបន្លែ | 0.03 | 0.17 | - | - | 5221 |
| ផ្សេងទៀត | 0.08 | 0.26 | - | - | 5221 |
| ដីស្រោចស្រព (ហិកតា) | 0.45 | 0.49 | - | - | 5221 |
| គម្រោងក្នុងភូមិ (% នៃគម្រោងសរុប) | | | | | |
| រដ្ឋាភិបាល៖ ការអភិវឌ្ឍកសិកម្ម | 0.10 | 0.30 | - | - | 293 |
| រដ្ឋាភិបាល៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | 0.23 | 0.42 | - | - | 293 |
| រដ្ឋាភិបាល៖ ការអភិវឌ្ឍទឹក | 0.09 | 0.28 | - | - | 293 |
| NGO៖ ការអភិវឌ្ឍកសិកម្ម | 0.14 | 0.34 | - | - | 293 |
| NGO៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | 0.11 | 0.30 | - | - | 293 |
| NGO៖ ការអភិវឌ្ឍទឹក | 0.08 | 0.28 | - | - | 293 |
| រដ្ឋាភិបាល៖ ជំនួយបច្ចេកទេសដាំដំណាំ សត្វចិញ្ចឹម ឬនេសាទ | 0.10 | 0.20 | - | - | 293 |

| អថេរក្រុមយកមកសិក្សា | | | | | 2004 & 2008 |
|---|---|---|---|---|---|
| | មធ្យម (mean) | គម្លាតស្តង់ដា | អប្បបរមា | អតិបរមា | ចំនួន |
| ភេទមេគ្រួសារ (1=បុរស) | 0.80 | 0.41 | - | - | 197 |
| អាយុមេគ្រួសារ (ឆ្នាំ) | 45.36 | 14.45 | 21 | 85 | 197 |
| មេគ្រួសារចេះអាន និងសរសេរ (%) | 0.78 | 0.42 | | | 197 |
| ទំហំគ្រួសារ (នាក់) | 4.77 | 1.73 | 1 | 12 | 197 |
| អត្រាសមាជិកក្នុងបន្ទុក (%) | 0.79 | 0.69 | 0 | 4 | 194 |
| កម្ចីផ្លូវការក្នុងមួយគ្រួសារ (ដុល្លារ) | 0.19 | 0.39 | - | - | 197 |
| កម្ចីក្រៅផ្លូវការក្នុងមួយគ្រួសារ (ដុល្លារ) | 0.26 | 0.44 | - | - | 197 |
| ទំហំក្បាលដី (ហិកតា) | 0.55 | 1.28 | 0.003 | 16 | 411 |
| ផលិតកម្មស្រូវ (តោន/ហិកតា) | 1.52 | 0.71 | 0 | 5 | 242 |
| ចំណូល (ដុល្លារ/ហិកតា) | 370.33 | 504.77 | 0 | 6150.06 | 381 |
| ប្រភេទដី (ហិកតា) | | | | | |
| ដីសើម | 0.60 | 0.48 | - | - | 411 |
| ដីស្ងួត | 0.07 | 0.25 | - | - | 411 |
| ទាំងដីសើម និងស្ងួត | 0.03 | 0.16 | - | - | 411 |
| **ចំការ** | 0.11 | 0.31 | - | - | 411 |
| សួនបន្លែ | 0.01 | 0.11 | - | - | 411 |
| ផ្សេងទៀត | 0.20 | 0.37 | - | - | 411 |
| ដីស្រោចស្រព (ហិកតា) | 0.32 | 0.47 | - | - | 411 |
| គម្រោងក្នុងភូមិ (% នៃគម្រោងសរុប) | | | | | |
| រដ្ឋាភិបាល៖ ការអភិវឌ្ឍកសិកម្ម | 0.15 | 0.36 | - | - | 27 |
| រដ្ឋាភិបាល៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | 0.34 | 0.49 | - | - | 27 |
| រដ្ឋាភិបាល៖ ការអភិវឌ្ឍទឹក | 0.11 | 0.33 | - | - | 27 |
| NGO៖ ការអភិវឌ្ឍកសិកម្ម | 0.22 | 0.44 | - | - | 27 |
| NGO៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | 0.11 | 0.33 | - | - | 27 |
| NGO៖ ការអភិវឌ្ឍទឹក | 0.19 | 0.40 | - | - | 27 |
| រដ្ឋាភិបាល៖ ជំនួយបច្ចេកទេសដាំដំណាំ សត្វចិញ្ចឹម ឬនេសាទ | 0.18 | 0.25 | - | - | 27 |

សម្គាល់៖ ១ដុល្លារ = ៤០៦៥រៀល ក្នុងឆ្នាំ២០០៨។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ក្នុងឆ្នាំ២០០៤ = ៨១ និង ក្នុងឆ្នាំ២០០៨ = ១៦៦ (សន្ទស្សន៍គោលឆ្នាំ២០០៦ = ១០០)។